ក្រសួងសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីឆ្លងមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០២នាក់ និងមិនមានករណីជាសះស្បើយ
# នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹកថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២៧៥នាក់** (ស្មើនឹង ៩៨,២១% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៥៤នាក់ និងបុរស ២២១នាក់។
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៨០នាក់** (ស្ត្រី ៥៦នាក់ និងបុរស ២២៤នាក់) ។
- អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ចំនួន **០៥នាក់** មានដូចខាងក្រោម៖
  - មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន ០១នាក់ (ជាស្ត្រីជនជាតិឥណ្ឌា)
  - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ ចំនួន ០១នាក់ (ជាបុរសជនជាតិចិន)
  - មន្ទីរពេទ្យបង្អែកខេត្តសៀមរាប ចំនួន ០២នាក់ (ជាបុរសជនជាតិហុងគ្រី និងបុរសជនជាតិបារាំង)
  - មន្ទីរពេទ្យបង្អែកខេត្តបាត់ដំបង ចំនួន ០១នាក់ (ជាស្ត្រីជនជាតិខ្មែរមកពីសហរដ្ឋអាមេរិក)

**២. ករណីឆ្លងមានវីរុសកូវីដ-១៩ ៖ ចំនួន ០២នាក់**

**២. ១. បុរសជនជាតិបារាំង** អាយុ ២៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ជាអ្នកធ្វើដំណើរពីប្រទេសបារាំង ដោយឆ្លងកាត់ប្រទេសសាំងហ្គាពួ តាមជើងហោះហើរ មកដល់កម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ សម្រាករងចាំលទ្ធផលតេស្តលើកទី១ នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ចំនួន ០២ យប់។ បន្ទាប់មក នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ គាត់បានចេញដំណើរពីរាជធានីភ្នំពេញតាមរថយន្ត **Larryta Minibus** នៅវេលាម៉ោង ១៨:៣០នាទីល្ងាច ទៅកាន់អាសយដ្ឋានខាងលើនៅខេត្តសៀមរាប ក្រោយពីធ្វើតេស្តលើកទី០១ ទទួលបានលទ្ធផល អវិជ្ជមានវីរុសកូវីដ-១៩។ រថយន្តនេះ ជិះមានគ្នា ០៤នាក់ (បុរសជនជាតិបារាំងខាងលើ អ្នកដំណើរ ០២នាក់ និងអ្នកបើកបរ) ហើយបុរសជនជាតិបារាំងនេះ ជិះនៅកៅអីខាងក្រោយគេបង្អស់ ព្រមទាំងបានពាក់ម៉ាស់ជាប់រហូតផងដែរ។ ពេលទៅដល់ផ្ទះ គាត់បានបន្តធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅផ្ទះរបស់គាត់នៅខេត្តសៀមរាប ហើយនៅថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ករបស់គាត់ដែលត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ គាត់ត្រូវបានធ្វើតេស្តឡើងវិញ ដោយបានទទួលលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ពីមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ហើយវត្ថុសំណាករបស់គាត់ត្រូវបានបញ្ជូនមកធ្វើការវិភាគបញ្ជាក់បន្ថែមនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ ដែលលទ្ធផលទទួលបាននៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ បានបង្ហាញបញ្ជាក់ថា **វិជ្ជមានវីរុសកូវីដ-១៩** ។ បច្ចុប្បន្ន អ្នកជំងឺ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាបតាំងពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០។

សូមកត់សម្គាល់ថា៖ អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើនេះ សរុបមានចំនួន ៩៨នាក់ (ក្នុងចំនួននេះ មានបុរសជនជាតិបារាំងខាងលើនេះដែរ) ដែលក្រុមការងារឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល បានធ្វើការស្រាវជ្រាវរក និងបានយកវត្ថុសំណាករបស់អ្នកដំណើរតាមជើងហោះហើរជាមួយអ្នកជំងឺនេះ បានចំនួន ៥០% ហើយលទ្ធផលតេស្តអ្នកទាំងអស់នេះ គឺ **អវិជ្ជមានវីរុសកូវីដ-១៩**។ ក្រុមការងារ នឹងបន្តយកវត្ថុសំណាកអ្នកដំណើរជាបន្តបន្ទាប់ទៀត ហើយក្រសួងសុខាភិបាល នឹងជម្រាបជូនសាធារណជននូវលទ្ធផល ប្រសិនបើរកឃើញមានអ្នកវិជ្ជមានវីរុសកូវីដ-១៩ លើបុគ្គលណាម្នាក់។ ដោយឡែក សម្រាប់ការស្រាវជ្រាវរកអ្នកប៉ះពាល់នៅខេត្តសៀមរាបបានបញ្ចប់រួចរាល់ ដោយក្រុមការងារមន្ទីរសុខាភិបាលខេត្តសៀមរាប បានរកឃើញអ្នកប៉ះពាល់ផ្ទាល់ចំនួន ០៣នាក់ (បុគ្គលិក ០២នាក់ (ស្រី ០១នាក់ ប្រុស ០១នាក់) និងបុរសជាមិត្តភ័ក្ត ០១នាក់) និងអ្នកប៉ះពាល់ប្រយោលចំនួន ១០នាក់ (ស្រី ០៩នាក់ និងប្រុស ០១នាក់) ដែលការវិភាគវត្ថុសំណាករបស់ពួកគាត់ទាំងអស់គ្នា គឺ **អវិជ្ជមានវីរុសកូវីដ-១៩**។

**២.២. ស្ត្រីជនជាតិឥណ្ឌា** អាយុ ៣៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ជាអ្នកធ្វើដំណើរពីប្រទេសឥណ្ឌា (ទីក្រុងដេលី) តាមជើងហោះហើរ មកដល់កម្ពុជានៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០។ ក្រោយពីធ្វើតេស្តលើកទី ០១ ទទួលបានលទ្ធផល អវិជ្ជមានវីរុសកូវីដ-១៩ គាត់បានបន្តធ្វើចត្តាឡីស័កចំនួន ១៨ថ្ងៃនៅក្នុងសណ្ឋាគារខាងលើនេះ ហើយកូនគាត់ ០២នាក់ ក៏ត្រូវបានគាត់ដាក់ឲ្យនៅបន្ទប់ដាច់ដោយឡែកពីគាត់ដែរ ហើយនៅថ្ងៃទី១៣នៃការធ្វើចត្តាឡីស័ករបស់គាត់ គឺត្រូវនឹងថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ វត្ថុសំណាករបស់គាត់ត្រូវបានយកទៅធ្វើតេស្តឡើងវិញ ក៏បានបង្ហាញលទ្ធផល **វិជ្ជមានវីរុសកូវីដ-១៩** ដែលផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ។ បច្ចុប្បន្ន អ្នកជំងឺ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ រីឯស្វាមីគាត់ បានចាកចេញពីកម្ពុជា ទៅប្រទេសឥណ្ឌាហើយមុនស្ត្រីរូបនេះ មានលទ្ធផលតេស្តវិជ្ជមានវីរុសកូវីដ-១៩ (មិនទាន់ត្រឡប់មកវិញ)។ រីឯបុរសត្រូវជាពូរបស់កូន និងកូន ០២នាក់ ត្រូវបានដឹកនាំយកមកដាក់ឲ្យធ្វើចត្តាឡីស័កនៅក្នុងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតរួចហើយដែរ នៅយប់ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០។

សូមកត់សម្គាល់ថា៖ អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺ សរុបមានចំនួន ៨៨នាក់ (ក្នុងចំនួននេះ មានស្ត្រីជនជាតិឥណ្ឌាខាងលើនេះដែរ)។ ក្រុមការងារឆ្លើយតបបន្ទាន់របស់ក្រសួងសុខាភិបាល នឹងបន្តការស្រាវជ្រាវរកអ្នកប៉ះពាល់ជាបន្តទៀត ហើយក្រសួង នឹងជម្រាបជូនសាធារណជននូវលទ្ធផលនៃការស្រាវជ្រាវ ប្រសិនបើមានអ្នកណាម្នាក់ ត្រូវបានរកឃើញថា វិជ្ជមានវីរុសកូវីដ-១៩។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខា ភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ... ៨៨៥ ៩៧០ / ៨៨៤ ៩០៩